# ប្រាសាទវត្តអធ្វា

តើពាក្យ អធ្វាមានន័យដូចម្តេច? អធ្វាជាភាសាសំស្ក្រឹត មានន័យថាផ្លូវឬដងផ្លូវ[១]។ ពាក្យនេះ គឺដូចគ្នានឹងពាក្យ អធ្វ័ន=អធ្វា[២] ដែលមានផ្លូវឬមិនទាល់។

ប្រាសាទវត្តអធ្វាមានទីតាំងស្ថិតនៅខាងលិចស្ទឹងសៀមរាប ចម្ងាយប្រហែល១គីឡូម៉ែត្រ ក្នុងភូមិកក្រាញ់ សង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប។ លោកហ្សង់ហ្គីយ៉េ ឡា បានចុះបញ្ជីប្រាសាទនេះក្នុងលំដាប់លេខ៥០០ ហើយហៅថា អធ្វាឬអបព្រះ (Athpraḥ)។[៣] ក្នុងសេចក្តីអធិប្បាយរបស់គាត់មានភាពល្អិតល្អន់អំពីរចនាសម្ព័ន្ធសំណង់ ប៉ុន្តែហាក់ដូចជាមានកំហុសបន្តិចចំពោះប្លង់ និងទិសដៅរបស់សំណង់ (រូបលេខ១) គឺប្លង់បានបង្ហាញថា ប្រាសាទទាំងមូល ពិសេសប្រាង្គកណ្តាលបែរទៅទិសខាងលិច។ ស្ថានភាពបច្ចុប្បន្ននៃរចនាសម្ព័ន្ធរបស់ប្រាសាទនេះបង្ហាញថា វាមិនត្រូវបានផ្សើរចរពល់នៅឡើយទេ ពោលគឺមានប្រហែល៣០ទៅ៤០ភាគរយនៅសល់ ទាំងការរៀបតម្លើងដុំថ្ម ការដាប់ចាំងជ្រុងនិងជញ្ជាំងថ្ម និងការធ្វើក្បាច់ចម្លាក់លម្អផ្សេងៗ។ ផ្នែកមួយចំនួនបានរៀបចំឡើងវិញ និងជួសជុលក្នុងសម័យបារាំង។

**រចនាសម្ព័ន្ធទូទៅរបស់ប្រាសាទ៖**

ប្រាសាទវត្តអធ្វា ជាប្រាសាទមួយទៀតក្រៅពីប្រាសាទអង្គរវត្តដែលមានច្រកចូលសំខាន់នៅទិសខាងលិច ពោលគឺបែរមុខទៅទិសខាងលិច។ តាមស្លាកស្នាមនៅសល់ មានគោបុរៈមួយនៅទិសខាងលិច បន្ទាប់មកព័ទ្ធដោយកសិណា១ជាន់ និងមានគោបុរៈមួយទៀតមុននិងដល់កំពែង១ជាន់របស់ប្រាង្គកណ្តាល។ កំពែងនេះសាងពីថ្មបាយក្រៀម ដោយមានទ្វារចូលនៅតាមទិសទាំង៤ ធ្វើអំពីថ្មភក់ពណ៌ប្រផេះ។ ប្រាង្គកណ្តាលមានទ្វារចូលពីទិសខាងលិច និងទ្វារបញ្ឆោត៣នៅតាមទិស៣ផ្សេងទៀត។ ផ្នែកខាងលិចបន្តដោយសំណង់មណ្ឌប ដែលទ្រដោយសសរនិងធ្នឹមមានចម្លាក់ដូចគ្នាស្ទើរទាំងស្រុងទៅនឹងប្រាសាទអង្គរវត្ត(រូបលេខ២)។ ផ្ទៃជញ្ជាំងក្បែរច្រកទ្វារមានលម្អដោយរូបអប្សរ៤(រូបលេខ៣)

---

[១] Gérard Huet 2020:34

[២] ជួន ណាត ១៩៦៧:១៦០៩

[៣] E. Lunet de Lajonquière 1911:117

និង២ជាគំនូសព្រាល មិនទាន់ធ្លាក់រូច។ អាគារមណ្ឌបនេះភ្ជាប់ទៅនឹងក្លោងទ្វារចូលខាងលិចដោយសំណង់ដូចស្ពានមួយ។ ប្រាង្គកណ្ដាលមានកំពូលដែលមានលក្ខណៈដូចគ្នាទៅនឹងកំពូលប្រាសាទអង្គរវត្ត(រូបលេខ២៤)។ មានអាគារ៤នៅអមសង្ខាងប្រាង្គកណ្ដាលនេះ និងបែរមុខទៅទិសខាងលិចទាំង៤។ អាគារ២នៅខាងកើតធ្វើពីថ្មភក់និងថ្មបាយក្រៀម (រូបលេខ២៥) រីឯអាគារ២នៅខាងលិចធ្វើពីថ្មភក់សុទ្ធ(រូបលេខ២៦)។ យើងមិនទាន់ដឹងពីមុខងារអាគារទាំង៤នេះទេ។ នេះជាចំណុចពិសេស១របស់ប្រាសាទវត្តអធ្វាដែលមានសំណង់៤អមសង្ខាង និងបែរមុខស្របទិសរបស់ប្រាង្គកណ្ដាល (ក្នុងករណីជាហោត្រៃ ជាទូទៅបែរបញ្ច្រាស់ជាមួយប្រាង្គកណ្ដាល)។

**តើប្រាសាទនេះកសាងឡើងនៅសម័យណាឬរាជ្យស្ដេចណា?**

យើងពុំទាន់មានសិលាចារឹកដើមណាមួយនិយាយអំពីការស្ថាបនាប្រាសាទនេះដោយព្រះរាជាអង្គណា ឬដោយនរណា ហើយនៅឆ្នាំណានោះទេ។ នៅលើសសររបស់មណ្ឌបខាងមុខប្រាង្គកណ្ដាលមានសិលាចារឹក៥ផ្ទាំង តែជាសិលាចារឹកចារឡើងនាសម័យក្រោយ ដោយនិយាយអំពីការធ្វើដង្វាយដល់ទីប្រាសាទ(ក្រោយអង្គរឬសម័យកណ្ដាល)នេះ។ បើយើងពិនិត្យមើលលើបែបផែននៃរចនាសម្ព័ន្ធផ្សេងៗរបស់ប្រាសាទនេះ ពិសេសគឺកំពូលនៃប្រាង្គកណ្ដាល និងចម្លាក់ទេពស្រី (អប្សរា) នៅអមសុំទ្វារបង្ហាញថាប្រាសាទនេះ មានលក្ខណៈដូចគ្នាទៅនឹងរចនាបថអង្គរវត្ត គឺដូចប្រាសាទអង្គរវត្ត ធម្មនន្ទ និងចៅសាយទេវតាជាដើម។ លោក ឡាហ្សង់ហ្គីយ៉េ បានប្រៀបធៀបលើចំនួនថ្នាក់(៥ថ្នាក់)[៨] របស់កំពូលប្រាង្គកណ្ដាល ហើយផ្ដល់សម្មតិកម្មជាចំណុចនៃការធ្វើកាលបរិច្ឆេទរបស់ប្រាសាទនេះ ដូចគ្នាទៅនឹងប្រាសាទអង្គរវត្ត។ ចំណុចដែលសំខាន់នោះ គឺយើងអាចលើកយកទិសដៅនៃប្រាសាទ ដែលគេបានស្ថាបនាឱ្យបែរមុខទៅរកទិសខាងលិចដូចប្រាសាទអង្គរវត្តដែរ។ ក្នុងករណីបែបនេះ យើងអាចសន្និដ្ឋានជាបណ្ដោះអាសន្នថា ប្រាសាទវត្តអធ្វា គឺអាចកសាងតំណាលគ្នានឹងប្រាសាទអង្គរវត្ត ឬក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២ (១១១៣គ.ស ដល់ ១១៥០គ.ស)។

[៨] E. Lunet de Lajonquière 1911:119

*តើប្រាសាទវត្តអធ្វាស្ថាបនាឡើងឧទ្ទិសដល់អ្វី ឬទេពអ្វី?*

*ដោយសារពុំមានសិលាចារឹករៀបរ៉ាប់អំពីការស្ថាបនា និងគោលបំណងនៃការឧទ្ទិសជាហេតុធ្វើឱ្យយើងពិបាកក្នុងការសន្និដ្ឋានអំពីចំណុចនេះណាស់។ យើងអាចទាញយកសម្មតិកម្មមួយចំនួន ដោយប្រៀបធៀបទៅនឹងប្រាសាទអង្គរវត្ត។ ចំណុចទី១ គឺប្រាសាទដែលបែរមុខទៅទិសខាងលិច អាចជាការឧទ្ទិសដល់ព្រះវិស្ណុ។ លោក អៃម៉ូនីញ៉េ បានសន្និដ្ឋានថា ប្រាសាទនេះកសាងឡើងឧទ្ទិសដល់ព្រហ្មញ្ញសាសនាបុរាណ តែក្រោយមកគឺជាទីកន្លែងដែលប្រតិបត្តិលើពុទ្ធសាសនា។[៥] នៅក្នុងប្រាង្គកណ្ដាលមានជើងទម្រមួយយ៉ាងធំ តែពុំមានបដិមាទេ។ ម្យ៉ាងវិញទៀត ក្រៅពីចម្លាក់រូបទេពអប្សរ និងក្បាច់ភ្ញីមួយចំនួនយើងពុំមានចម្លាក់តួអង្គ ឬរឿងទេវកថាផ្សេងៗដូចនៅប្រាសាទក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២ទេ។ ក្នុងករណី១ យើងអាចឱ្យសម្មតិកម្មជាបណ្ដោះអាសន្នថា ប្រាសាទវត្តអធ្វានេះអាចកសាងឡើងឧទ្ទិសដល់ព្រះវិស្ណុ និងជាប្រាសាទគោលដៅនៃសេចក្ដីស្លាប់ ដូចប្រាសាទអង្គរវត្តដែរ។*

*តើសិលាចារឹកលើសសររបស់ប្រាង្គកណ្ដាលរៀបរាប់អំពីអ្វី?*

*សិលាចារឹកចំនួន៥ផ្ទាំង (រូបលេខ៧) អធិប្បាយដំបូងដោយលោក អៃម៉ូនីញ៉េ និងក្រោយមកបានចុះបញ្ជីជាសិលាចារឹកកម្ពុជាលេខ* K.261[៦] *ដោយលោកសឺដេស។ ប៉ុន្តែជនជាតិបារាំងទាំងនេះពុំបានសិក្សាបកប្រែលម្អិតអត្ថន័យសិលាចារឹកទាំងនេះទេ។ ក្រោយមកលោកស្រី ពៅ សាវរស់[៧] បានសិក្សាបកប្រែសិលាចារឹកទាំង៥ផ្ទាំងនេះ។ សិលាចារឹកទាំងនេះមានមកាលបរិច្ឆេទចន្លោះឆ្នាំគ.ស ១៥៧៨ដល់១៦៧៧ ហើយមានអត្ថន័យស្មើដូចគ្នា គឺនិយាយអំពីការគោរព ការថ្វាយ និងការបួងសួងអោយរួចផុតទោសកម្មពារ ចាកចេញពីឋាននរកទាំងឡាយ និងបានដល់ទីឋានសួគ៌ និងទាន់ព្រះសិរមេត្រីយ។*

---

[៥] E. Aymonier, (1900:399)

[៦] G. Cœdès, (1966:119)

[៧] Pou Saveros, (1977:151-166)

ក្រៅពីសិលាចារឹកសម័យកណ្ដាលទាំងនោះ យើងសង្កេតឃើញមានសិលាចារឹកខ្លីៗ ឬអក្សរថ្មដែលមាននៅលើផ្ទៃជញ្ជាំងថ្មដែលគេនៅមិនទាន់កាត់តម្រឹម ឬឆ្លាក់ជាក្បាច់នៅឡើយ។ អក្សរទាំងនោះ គឺជាសញ្ញាឬកំណត់សំគាល់អំពីមនុស្សដែលកាត់ថ្ម ឬក៏អាចជាឈ្មោះនៃការដ្ឋានយកថ្មដែលគេយកមក។ បើយើងប្រៀបធៀបទៅនឹងអក្សរថ្មដែលគេជួបប្រទះនៅប្រាសាទតុបលិច[៨] ឬសំណង់កណ្ដាលស្រះស្រង់[៩] គឺវាមានលក្ខណៈច្បាស់ លាស់ជាងអក្សរនៅលើថ្មនៅទីតាំងទាំង២។ ឧទាហរណ៍ មានពាក្យខ្លះដែលយើងឃើញសរសេរដូចគ្នានៅលើថ្មផ្សេងគ្នា ដូចជា ពាក្យ *តកល* ជាដើម (រូបលេខ៨)។

អត្ថបទនេះពុំបានអធិប្បាយឱ្យបានលម្អិត លើរចនាសម្ព័ន្ធប្រាសាទទាំងមូលទេ។ យើងនឹងសិក្សាបន្តអំពីមូលហេតុមួយចំនួនដើម្បីបកស្រាយលើបញ្ហា និងទស្សនៈនៃការសាងសង់ប្រាសាទនេះ។ ពិសេសគឺដើម្បីបង្ហាញថា តើប្រាសាទនេះកសាងឡើងក្នុងពេលណាឱ្យច្បាស់? ដើម្បីអ្វី ឬឧទ្ទិសដល់ទេពអ្វី? ហើយហេតុអ្វីបានជាការសាងសង់មិនទាន់បញ្ចប់?

---

[៨] Sok Keo Sovannara (2015:49-55)

[៩] សុខ កែវ សុវណ្ណារ៉ា (២០២០)



រូបលេខ១៖ប្លង់ប្រាសាទវត្តអធ្វា
(គូរដោយលោក ឡាហ្សង់ហ្គីយ៉េ)



រូបលេខ២ ៖ក្បាលសសរនិងធ្នឹមមានចម្លាក់
ដូចប្រាសាតអង្គរវត្ត



រូបលេខ៣៖ ចម្លាក់រូបទេពអប្សរនៅលើជញ្ជាំងអាគ្នេយ៍របស់អគារមណ្ឌបខាងលិច
(រចនាបថអង្គរវត្ត)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ៤៖ ប្រាង្គកណ្ដាល និងកំពូលមានរូបរាងដូចកំពូលប្រាសាទអង្គរវត្ត



រូបលេខ៥៖ អគារខាងកើត ជ្រុងឥសាន្ត ធ្វើពីថ្មភក់និងថ្មបាយក្រៀម

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ២៦៖ អគារខាងលិច ជ្រុងអាគ្នេយ៍ ធ្វើពីថ្មភក់



រូបលេខ២៧៖ សិលាចារឹកសម័យកណ្ដាល នៅលើសសរខាងក្នុងសំណង់មណ្ឌប



រូបលេខ៨៖ អក្សរលើថ្មមិនទាន់ធ្វើរួច (តលក)

## ឯកសារយោង

ជួន ណាត

១៩៦៧. វចនានុក្រមខ្មែរ, ពុទ្ធសាសនបណ្ឌិត, ភ្នំពេញ។

សុខ កែវ សុវណ្ណារ៉ា

២០២០. *អក្សរថ្មនៅលើថ្មសំណង់កណ្តាលស្រះស្រង់,ក្នុងអត្ថបទស្រាវជ្រាវថ្មី និងគួរពិចារណា*, លេខ២២, សៀមរាប។

E. Aymonier

1900. Le Cambodge, Tome II, Paris.

G. Cœdès

1966. *Inscription du Cambodge*, Volume VIII, Paris.

Pou Saveros

1977. *Inscriptions en Khmer Moyen de Vat Athvea*, BEFEO, Tome LXIV, pp.151-166.

Sok Keo Sovannara

2015. *The Western Top Temple´s Stone Blocks-Preliminary Introduction to the Inscriptions, Graffiti Marks and Sketched Designs*, in Annual Report on the Research and Restoration Work of the Western Prasat Top, NRICP, p.49-55, Japan.

Gérard Huet

2020. *Dictionnaire Sanskrit-Français*.

E. Lunet de Lajonquière

1911. *Inventaire Descriptif des Monuments du Cambdoge*, Tome III, PEFEO, Paris p.117-120.

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា